# ជំងឺកូរ៉ូណាវីរុស (COVID-19) នៅក្នុងក្រុង LOWELL

ជំងឺកូរ៉ូណាវីរុស ឬ COVID-19 គឺជាវីរុសប្រព័ន្ធដង្ហើម ដែលជាទូទៅឆ្លងពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត នៅពេលមនុស្ស ដែលបានកើតជំងឺ ក្អក ឬកណ្តាស់ គឺស្រដៀងគ្នានឹងជំងឺគ្រុនផ្តាសាយធំ ឬជំងឺប្រព័ន្ធដង្ហើម ផ្សេងៗទៀតដែរ។ ករណីដំបូងនៃ COVID-19 បានបញ្ជាក់ នៅក្នុងរដ្ឋម៉ាស្សាជូសេត្ត ត្រូវបានរាយការណ៍នៅថ្ងៃទី 1 ខែកុម្ភៈ 2020។ ចំនួនករណីបានបញ្ជាក់ នៅក្នុងរដ្ឋម៉ាស្សាជូសេត្ត បានចាប់ផ្តើមកើនឡើងយ៉ាងរហ័ស ក្នុងដើមខែមីនា ហើយករណីដំបូងបានបញ្ជាក់ នៅក្នុងក្រុង Lowell ត្រូវបានរាយការណ៍នៅថ្ងៃទី 15 ខែមីនា 2020។

បានដឹកនាំដោយក្រសួងសុខភាព និងក្រុមចាត់ចែងភាពអាសន្ន ក្រុង Lowell បានចាត់វិធានការតបឆ្លើយយ៉ាងស្វាហាប់ និង ខំប្រឹងប្រែងប្រុងប្រៀប ចាប់តាំងពីមានវិបត្តិនៃជំងឺកូរ៉ូណាវីរុស។ ការខំប្រឹងប្រែងទាំងនេះ បានកើតឡើងដោយមានការសំរបសំរួល ជាមួយនឹងភ្នាក់ងាររដ្ឋ និងដៃគូខាងសុខភាពក្នុងមូលដ្ឋាន រួមទាំង មន្ទីរពេទ្យ Lowell General, Trinity EMS ហើយនិង Lowell Community Health Center ព្រមទាំងក៏មានលទ្ធផលជាវិជ្ជមាន ក្នុងការបង្កបង្កើត ដែលបានធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធ នៃសុខភាពរបស់សហគមន៍បានល្អប្រពៃ រួមទាំងបានពង្រីកការធ្វើតេស្ត និងលទ្ធភាពគ្រែមន្ទីរពេទ្យ។

## រោគសញ្ញា

រោគសញ្ញានៃជំងឺកូរ៉ូណាវីរុស អាចនឹងលេចឡើងក្នុងពេលពីរ ទៅដប់បួនថ្ងៃ នៃការឆ្លងវីរុស ហើយក៏មាន៖ គ្រុន, ក្អក, ដកដង្ហើមផុតៗ, ពិបាកដកដង្ហើម, ឈឺបំពង់ក, ឈឺក្បាល, ឈឺសាច់ដុំ, ស្រៀវស្រាញ, ញាប់ញ័រដោយស្រៀវស្រាញ មានបាត់ៗ, បាត់បង់រសជាតិ ឬក្លិន។ ភាពធ្ងន់ធ្ងរនៃរោគសញ្ញាទាំងនេះ មានខុសៗគ្នាក្នុងបណ្តាអ្នកជំងឺ។

ប្រជាជននៅរដ្ឋម៉ាស្សាជូសេត្ត ដែលមានរោគសញ្ញាដូចជំងឺ COVID អាចនឹងសំរេច បើសិនការធ្វើតេស្ត ឬការយកចិត្តទុកដាក់ ថែទាំសុខភាពផ្សេងទៀត គឺបានតម្រូវ ដោយប្រើឧបករណ៍តាមបណ្តាញ ដែលមានតាមរយៈ Buoy Health ដែលអាចចូល មើលបាន នៅ៖ buoyhealth.com/mass។ ប្រព័ន្ធនេះមិនគួរបានប្រើ ក្នុងស្ថានភាពអាសន្នទេ ហើយក៏មិនជំនួសឱវាទនៃ អ្នកវិជ្ជាជីវៈពេទ្យ និងរោគវិនិច្ឆ័យឡើយ។

## ការធ្វើតេស្ត

ការធ្វើតេស្តឥតគិតថ្លៃ គឺមានសំរាប់ប្រជាជនទាំងអស់ រួមទាំងអស់អ្នកដែលពុំមានរោគសញ្ញា តាមរយៈការផ្តួចផ្តើមរបស់រដ្ឋ ហៅថា បញ្ឈប់ការឆ្លងរាលដាល ។ ចាប់ផ្តើមនៅថ្ងៃច័ន្ទទី 20 ខែកក្កដា ប្រតិបត្តិការធ្វើតេស្តចល័តមួយ ត្រូវបានស្ថាបនាឡើង ដោយសហការជាមួយ Lowell Community Health Center និង Trinity EMS និងបានបោះទីតាំង នៅនឹងកន្លែង ពាសពេញក្រុង ចំនួនរយៈពេលប្រាំថ្ងៃ រហូតដល់ថ្ងៃទី 14 ខែសីហា។ ចុចទីនេះ សំរាប់កាលវិភាគសព្វគ្រប់នៃទីកន្លែងធ្វើតេស្ត នឹងកើតឡើង។

ម៉ោងធ្វើតេស្តនៅគ្រប់កន្លែងទាំងអស់ នឹងពីម៉ោង 3:00 រសៀល – 6:00 ល្ងាច នៅថ្ងៃច័ន្ទ និងថ្ងៃអង្គារ ហើយម៉ោង 9:00 ព្រឹក – 12:00 ថ្ងៃត្រង់ នៅថ្ងៃពុធ ព្រហស្បតិ៍ និងថ្ងៃសុក្រ។ ការធ្វើតេស្ត បើកឡានចូល និងដើរចូលមក នឹងមាននៅគ្រប់កន្លែង ទាំងអស់ លើកលែងតែសំរាប់សមាគមខ្មែរ Cambodian Mutual Assistance Association ដែលកន្លែងធ្វើតេស្ត នឹងសំរាប់តែដើរចូលមកប៉ុណ្ណោះ។ ការចុះឈ្មោះជាមុន ត្រូវបានឲ្យអនុស្វាសន៍យ៉ាងខ្លាំង ដើម្បីការពារការពន្យារពេល ក្នុង ដំណើរការធ្វើតេស្ត ថ្វីបើមិនបានតម្រូវក៏ដោយ។ ដើម្បីចុះឈ្មោះជាមុន សូមទូរស័ព្ទទៅ Lowell Community Health Center តាមលេខ 978-937-9700 ចន្លោះម៉ោង 8:30 ព្រឹក និង 5:00 រសៀល។ សូមកំណត់ថាការចុះឈ្មោះជាមុន គឺជាការណាត់

ពេលជួប និងមិនធានាពីការធ្វើតេស្ត នៅពេលជាក់លាក់ឡើយ។
ត្បិតកន្លែងទាំងអស់ គឺនៅខាងក្រៅ ម្ល៉ោះហើយការធ្វើតេស្ត គឺពឹងលើធាតុអាកាស។ សូមឆែកមើលសេចក្តីជូនដំណឹងពីការ លុបចោល មុននឹងទៅកន្លែងធ្វើតេស្ត អំឡុងពេលព្រឹត្តិការណ៍មានធាតុអាកាសមិនល្អ។

ការធ្វើតេស្តឥតគិតថ្លៃ ក៏មានតាមរយៈការណាត់ពេលជួបនៅ Lowell Community Health Center ស្ថិតនៅ 161 Jackson Street នៅថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ពីម៉ោង 9:00 ព្រឹក ដល់ 1:00 រសៀល។
ដើម្បីស្វែងយល់ថែមទៀត អំពីកម្មវិធីបញ្ឈប់ការរាលដាល ទស្សនា៖ mass.gov/stopthespread

## ការត្រួតមើលករណី និងការតាមដានអ្នកទាក់ទង

ក្រសួងសុខភាពរបស់ក្រុង ត្រូវបានជំរាបព័ត៌មានសំខាន់ៗ អំពីប្រជាជនម្នាក់ៗនៅក្រុង Lowell ពីការធ្វើតេស្តដែលវិជ្ជមានជំងឺ COVID-19។ ពេទ្យខាងសុខភាពសាធារណៈ ទាក់ទងអ្នកជំងឺម្នាក់ៗ ដើម្បីធ្វើឲ្យប្រាកដ ថាគេដឹងពីការតម្រូវនៃការនៅដាច់ឡែក និង ដើម្បីសំរេចអំពីមនុស្សផ្សេងៗ ដែលគេបានទាក់ទងជាមួយ។ តាមរយៈដំណើរការមួយហៅថា ការតាមដានអ្នកទាក់ទង នោះ បុគ្គលិក របស់ក្រសួង ធ្វើការទំនាក់ទំនង ជាមួយនឹងអ្នកទាក់ទងនីមួយៗ ដើម្បីជំរាបគេអំពីពីធីការ ដែលគេបានឆ្លងមេរោគវីរុស។ ការខំប្រឹងប្រែង ទាំងនេះ នៅពេលថ្មីៗនេះត្រូវបានគាំទ្រដោយការខំប្រឹងប្រែង ចាប់ផ្តើមទូទាំងរដ្ឋ ដោយអភិបាលកិច្ចនៃលោក Baker ដោយមានការសំ របសំរួលជាមួយនឹង Partners in Health។ ការតាមដានអ្នកទាក់ទង គឺជាមុខងារនៃសុខភាពសាធារណៈដ៏សំខាន់ ក្នុងការទប់ស្កាត់នូវ ការឆ្លងរាលដាលនៃជំងឺកូរ៉ូណាវីរុស។ វាគឺជាសារៈសំខាន់ ថាប្រជាជនដែលបានទាក់ទង ដោយពេទ្យសុខភាពសាធារណៈ ត្រូវសហការ យ៉ាងពេញលេញ។

## ចំណាត់ការបន្តរបន្ថយទូទាំងរដ្ឋ និងបទបញ្ជា

លោកអភិបាលរដ្ឋ Baker បានប្រកាសសភាពអាសន្ន ក្នុងរដ្ឋម៉ាស្សាជូសេត្ត នៅថ្ងៃទី 10 ខែមីនា 2020 ដោយធ្វើឲ្យសមត្ថភាព របស់ អភិបាលកិច្ច ដើម្បីតបឆ្លើយចំពោះវិបត្តិជំងឺកូរ៉ូណាវីរុស ប្រសើរឡើង។

នៅថ្ងៃទី 24 ខែមីនា 2020 លោកអភិបាលរដ្ឋ Baker បានចេញបទបញ្ជាឲ្យបិទពាណិជ្ជកម្មមិនចាំបាច់ និងប្រតិបត្តិការ និងក៏បានចេញ បង្គាប់ឲ្យប្រជាជនទាំងអស់នៅផ្ទះ។

នៅថ្ងៃទី 18 ខែឧសភា អភិបាលកិច្ចបានប្រកាស ពីគំរោងការចាប់ផ្តើមបើកឡើងវិញរបស់រដ្ឋ ជាបួនដំណាក់កាល ដែលបាន អនុញ្ញាត ឲ្យពាណិជ្ជកម្មខ្លះ ធ្វើប្រតិបត្តិការ និងចាប់ផ្តើមឡើងវិញ នៅក្រោមគោលការណ៍ណែនាំសុវត្ថិភាពដ៏តឹងរ៉ឹង។ នៅបច្ចុប្បន្ននេះ រដ្ឋស្ថិតក្នុង ដំណាក់កាលទី 3 នៃដំណើរការបើកឡើងវិញ។

សំរាប់ព័ត៌មានបន្ថែម ស្តីពីដំណាក់កាលរបស់អភិបាលកិច្ច នៃគំរោងការបើកឡើងវិញ រួមទាំងគោលការណ៍ណែនាំ សំរាប់ផ្នែក ជាក់លាក់ ចុចទីនេះ។

នៅថ្ងៃទី 6 ខែឧសភា លោកអភិបាលរដ្ឋ Baker បានចេញបទបញ្ជា តម្រូវឲ្យប្រើម៉ាស្ក ឬរបាំងមុខ នៅក្នុងទីសាធារណៈ ដែល មិនអាច រក្សាការនៅឃ្លាតពីគ្នា បានដោយសមរម្យ។ បទបញ្ជានៅតែមានប្រសិទ្ធភាពដដែល។ ចុចទីនេះ សំរាប់ព័ត៌មានបន្ថែម ស្តីពីបទបញ្ជា។

## ចំណាត់ការបន្តរបន្ថយទូទាំងរដ្ឋ និងបទបញ្ជា

ចាប់ផ្តើមនៅថ្ងៃអង្គារទី 21 ខែកក្កដា សាលាក្រុង និងអាគារផ្សេងទៀតរបស់ក្រុង នឹងបើកសំរាប់សាធារណជន នៅថ្ងៃអង្គារ ពីម៉ោង 8ព្រឹក-8យប់ និងថ្ងៃព្រហស្បតិ៍ ពីម៉ោង 8ព្រឹក-5ល្ងាច។ ក្រសួងទាំងអស់របស់ក្រុង នឹងមានសំរាប់ជួយប្រជាជន ពីចំងាយ នៅក្រៅម៉ោង ទាំងនេះ អំឡុងម៉ោងធ្វើការធម្មតា។

ក្រុង Lowell សូមស្នើមកថា ប្រជាជន និងបុគ្គលផ្សេងៗទៀត ដែលស្វែងមកចូលរួម ទាក់ទងនឹងកិច្ចការក្រុង  បន្តធ្វើដូច្នេះ ពីចំងាយ នៅពេលអាចធ្វើបាន; តាមបណ្តាញ, តាមទូរស័ព្ទ, តាមយៈប្រៃសណីយ៍, ឬដោយប្រើប្រអប់ទំលាក់ចុះរបស់ក្រុង ដែលជាប់លាប់ ស្ថិតនៅផ្លូវចូលនៃសាលាក្រុង នៅ JFK Plaza។ ក្រសួងទាំងអស់របស់ក្រុង នឹងនៅបើកដដែល និងមានដើម្បី ជួយប្រជាជន ពីចំងាយ អំឡុងម៉ោងធ្វើការធម្មតា។

សមាជិកនៃសាធារណជន ដែលចូលមកអាគារណាមួយរបស់ក្រុង ត្រូវតែប្រកាន់ខ្ជាប់ ចំពោះគោលការណ៍ណែនាំ នៃគម្លាតរូបកាយ , រក្សាចំងាយប្រាំមួយហ្វីតពីគ្នា ពីបុគ្គលិកក្រុង និងសមាជិកនៃសាធារណជនផ្សេងទៀត ហើយនឹងបានតម្រូវឲ្យពាក់ របាំងមុខ សំរាប់ រយៈពេលនៃការជួបពិគ្រោះរបស់គេ លុះត្រាតែគេមិនអាចធ្វើបាន ដោយព្រោះលក្ខណៈសុខភាព។ បុគ្គលទាំង ឡាយ ត្រូវបានសូមឲ្យ ជៀសវាង ការចូលទៅអាគាររបស់ក្រុង បើសិនគេឈឺថ្កាត់ ឬមានរោគសញ្ញានៃជំងឺ COVID-19។

សាលាក្រុង និងអាគារផ្សេងទៀតទាំងអស់របស់ក្រុង ត្រូវបានបិទសំរាប់សាធារណជនពីដំបូង ដោយព្រោះកង្វល់ទាក់ទង ចំពោះការឆ្លង រាលដាលនៃជំងឺ COVID-19 នៅថ្ងៃច័ន្ទទី 16 ខែមីនា 2020។

ទីមនោរម្យសាធារណៈ ដែលបានបិទសំរាប់សាធារណជនពីមុន រួមទាំងទីធ្លាលេង និងផ្ទៃលេង ដូចជាកន្លែងលេងបាល់បោះ ឥឡូវនេះ បានបើកឡើងវិញ សំរាប់សាធារណជន។
សំរាប់សំណួរ ទាក់ទងនឹងប្រតិបត្តិការរបស់ក្រុង ហៅលេខ៖ 978-674-4400។

## ការពារខ្លួនអ្នក និងជួយបញ្ឈប់ការឆ្លងរាលដាល

របៀបដែលមានប្រសិទ្ធិភាពបំផុត ដើម្បីរក្សាឲ្យសុខសប្បាយ អំឡុងពេលការរាតត្បាតនៃជំងឺកូរ៉ូណាវីរុស គឺដើម្បីដាក់កម្រិតហានិភ័យរបស់អ្នក សំរាប់ការឆ្លង ដែលមានន័យថានៅផ្ទះ នៅពេលណាអាចធ្វើបាន និងដាក់កម្រិតការទាក់ទងជាមួយនឹងបុគ្គលដែលក្រៅពីក្រុមគ្រួសាររបស់អ្នក។ អនុសាសន៍ផ្សេងទៀតមកពី CDC និងអាជ្ញាធរសុខភាពផ្សេងទៀត រួមមាន៖

- លាងដៃរបស់អ្នក ជាមួយនឹងសាប៊ូ និងទឹក ឲ្យបានញឹកញាប់ យ៉ាងតិចបំផុត 20 វិនាទី
- បើសិនគ្មានសាប៊ូ និងទឹកទេ ប្រើទឹកអនាម័យដៃមានជាតិអាកុល មានជាតិអាកុលតិចបំផុត 60%។
- ជៀសវាងការប៉ះភ្នែក ច្រមុះ និងមាត់របស់អ្នក ដោយដៃដែលមិនបានលាង
- ពាក់ម៉ាស្កុ/របាំងមុខ នៅពេលចេញពីផ្ទះរបស់អ្នក។
- ជូតសំអាត និងរំងាប់មេរោគ នូវវត្ថុ និងផ្ទៃដែលបានប៉ះញឹកញាប់។
- ជៀសវាងជួបមនុស្សដែលឈឺថ្កាត់។
- នៅផ្ទះ នៅពេលអ្នកឈឺថ្កាត់។

## ព័ត៌មានបន្ថែម

ប្រជាជនដែលមានសំណួរ ឬកង្វល់អ្វីមួយ ទាក់ទងនឹងជំងឺកូរ៉ុណាវីរុស ត្រូវបានជំរុញទឹកចិត្តឲ្យទាក់ទង ក្រសួងសុខភាពរបស់ក្រុង Lowell តាមលេខ 978-674-4010 ឬទាក់ទងខ្សែ 2-1-1 ដែលបានរៀបចំឡើងដោយរដ្ឋ។ ប្រជាជនរដ្ឋម៉ាស្សាជូសេត្ត ត្រូវបានជំរុញទឹកចិត្ត ឲ្យចុះឈ្មោះសំរាប់សភាពការណ៍ មកពីរដ្ឋ ដោយវាយពាក្យ COVIDMA ទៅលេខ 888-777។